# របៀបបើកមុខចៀរដំបូង

ដោយៈ ការិយាល័យសរីរវិទ្យា-អាជីវកម្ម នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ

## សេចក្តីផ្តើម

ផ្នែកសំខាន់ៗបំផុតនៃដើមកៅស៊ូស្ថិតនៅសំបកដែលនៅខាងក្នុងមានសរីរាង្គផលិតទឹកជ័រ។ អ្នកដាំកៅស៊ូត្រូវយកចិត្តទុកដាក់លើរបៀបបើកមុខជ័រដំបូងមិនបានរៀបចំទៅតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវទេ ផលិតកម្មកៅស៊ូនឹងថយចុះ។ ដូច្នេះម្ចាស់ ឬអ្នកទទួលខុសត្រូវចម្ការកៅស៊ូមានភារកិច្ចរៀបចំបើកមុខចៀរដំបូងឲ្យបានត្រឹមត្រូវទៅតាមបច្ចេកទេសដែលបានកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ។

## ទម្រង់ទូទៅនៃសំបកដើមកៅស៊ូ

នៅក្នុងដើមកៅស៊ូ ទឹកជ័រត្រូវបានផ្ទុកនៅក្នុងសរសៃជ័រ។ ការធ្វើឲ្យសរសៃជ័រដាច់បានបណ្តាលឲ្យទឹកជ័រហូរចេញមកក្រៅ។ដើមកៅស៊ូត្រូវបានធ្វើអាជីវកម្មដោយការចៀរសំបកក្នុងរយៈពេលទៀងទាត់ តាមមុខចៀរនៅលើដើមជារង្វង់គូទខ្យង។ ចំណេះដឹងអំពីទម្រង់នៃសំបកដើមកៅស៊ូមានសារសំខាន់ណាស់ ដើម្បីយល់ដឹងពីលំហូរនៃទឹកជ័រ។ ភាគច្រើននៃជាលិកាដើមកៅស៊ូ គឺកើតចេញពីដំណើរការនៃមេជាលិកាខាង ដែលគេហៅថា កំប្រូម(Cambium) ។ស្រទាប់កំប្រូមនេះបានបង្កើតឲ្យមាននូវ សាច់ឈើ នៅផ្នែកខាងក្នុង និងស្រទាប់ស្រោយ ផ្នែកខាងក្រៅ។ គឺនៅក្នុងស្រទាប់ស្រោយនេះហើយដែលបណ្តាលសរសៃទឹកជ័រស្ថិតនៅ។

## លក្ខណៈវិនិច្ឆ័យនៃ ការបើកមុខចៀរដំបូង




ដើមកៅស៊ូដែលអាច បើកមុខចៀរបានត្រូវមានរង្វង់ដើម ៥០ ស.ម នៅកម្ពស់ ១០០ ស.ម ពីដី។ ចម្ការដែលអាចចាប់ផ្តើមបើកមុខចៀរលុះត្រាមានចំនួនដើមដែលមានរង្វង់ដូចខាងលើស្មើ៧៧% នៃចំនួនដើមទាំងអស់នៅក្នុងចម្ការទើបមានប្រសិទ្ធភាពសេដ្ឋកិច្ច។

## របៀបបើកមុខចៀរ

ដំបូងត្រូវជ្រើសរើសដើមកៅស៊ូ ដែលមានរង្វង់ ៥០ ស.ម នៅកម្ពស់ ១០០ ស.ម ពីដី បន្ទាប់មកគេដៅនៅកម្ពស់ ១៧០ ស.ម ពីដីនូវសញ្ញា ឬចំណុចសម្គាល់ពណ៌ក្រហមលើដើមដែលមានទំហំត្រូវខ្នាត រួចគូសបន្ទាត់ឈរពីឈមគ្នាតាមបណ្តាយដើម ដែលមានចំណុចក្រហមសម្គាល់នោះដើម្បី



*ការដៅចំណុចសម្គាល់ដើមសម្រាប់បើកមុខចៀរ*



*ការចែកផ្ទាំងសំបកជាពីរផ្នែកស្មើគ្នា*

ចែកផ្ទាំងមុខចៀរជាពីរផ្ទាំងប៉ុនគ្នា ដោយដាក់ម៉ែត្រឈើដែលមានប្រវែងពីរម៉ែត្រផ្ទឹបជាប់ ហើយបញ្ឈរស្របនឹងស្ថានភាពដើមឲ្យចំពាក់កណ្តាលរួចធូតឲ្យមុតជ្រៅបន្តិចតាមម៉ែត្រឈើគួរកត់សម្គាល់ថា បន្ទាត់ឈរទាំងពីរមានទិសបែរទៅរកបន្ទាត់ទ្រូងនៃរងកៅស៊ូ។

បន្ទាប់មក គេយកឧបករណ៍គំរូក្រិតមុខចៀរ(ទង់ជ័យ) ធ្វើអំពីដែកបន្ទះមកដាក់ផ្ទឹបទៅនឹងដើមកៅស៊ូត្រង់ចំណុចសម្គាល់១.៣ម ពីដីរួចគូសគំនូសតាមដែកបន្ទះដើម្បីបង្កើតមុខចៀរដែលមានមុំ៣០ អង្សា។ ទន្ទឹមនឹងនេះគេក្រិតសំបកសម្រាប់ចៀររយៈពេល១ខែ-៣ខែ ឬ៦ខែ និង១ឆ្នាំ។ ចំនៀរចំណាយសំបកក្នុង១ឆ្នាំ ចំពោះដើមកៅស៊ូទើបបើកមុខចៀរ



*ឧបករណ៍គំរូក្រិតមុខចៀរ*



*ការក្រិតសំបកសម្រាប់ចៀរ*

ថ្មីគឺ ១៣ ស.ម។

## ការបំពាក់ឧបករណ៍ត្រង់ជ័រ

ប្រវែងពីមុខចៀរមកចានត្រង់មានប្រវែង៣៥ ស.ម។ នៅចន្លោះពីមុខចៀរមកស្លាបព្រាមានប្រវែង១៥ ស.ម គេធូតចង្អូរឲ្យជ្រៅបន្តិច ដើម្បីឲ្យជ័រហូរចុះមកក្រោមកាត់តាមស្លាបព្រារួចស្រកធ្លាក់ក្នុងចាន។



*១៥ស.ម*

*២០ស.ម*

*ការបំពាក់ស្លាបព្រា លួសចងចាន និងចានត្រងជ័រ*



## ការចាប់ផ្តើមបើកមុខចៀរជ័រ





មុខនឹងចាប់ផ្តើមដំណើរការចៀរជ័រដំបូងគេត្រូវបើកមុខចៀរចំនួន៣ពន្លាកជាមុនសិន ដោយចៀរតាមលំនាំខ្នាតមុំចំណោតមុខចៀរ ដែលបានរៀបរាប់នៅក្នុងរបៀបបើកមុខចៀរខាងលើ និងអនុវត្តតាមជំហ៊ានដូចខាងក្រោមៈ

**ពន្លាកទី១៖**

ចៀរសើរៗតាមគំរូចំណោតមុខចៀរ។

**ពន្លាកទី២៖**

ចៀរតាមលំនាំនៃពន្លាកទី១ឲ្យបានជ្រៅជាងពន្លាកទី១ បន្តិច។

**ពន្លាកទី៣៖**

រុញពន្លាកចៀរឲ្យដល់ជម្រៅតាមបទដ្ឋានដែលបានកំណត់ទុកគឺទុក១ម.ម ពីស្រទាប់កំប្បូម( Cambium )។

